# ចម្លាក់ក្រឹស្នហែកនាគកាលិយ

ព្រះក្រឹស្ន ជាអវតារមួយក្នុងចំណោមអវតារទាំងដប់របស់ព្រះវិស្ណុ។ នៅក្នុងទេវកថារឿងព្រះក្រឹស្ន មានបង្ហាញអំពីកំណើតរបស់ទ្រង់ ឈុតព្រះអង្គសម្លាប់កម្ស ឈុតក្រឹស្នទ្រភ្នំគោវធ៌ន និងឈុតទ្រង់សម្លាប់សត្វក្នុងទម្រង់ជាបិសាចផ្សេងៗពីគ្នា ដូចជាសម្លាប់សេះកេសិន គោអារិស្ត និងដំរីកុវលយជាដើម។ ដោយឡែក នៅក្នុងអត្ថបទខ្ញុំនេះ យើងនឹងបរិយាយតែចម្លាក់ព្រះក្រឹស្នហែកនាគកាលិយជាពីរចំណែកតែប៉ុណ្ណោះ។

គម្ពីរបុរាណផ្សេងៗដែលនិយាយសរសើរព្រះក្រឹស្ន និងឈុតដែលព្រះក្រឹស្នហែកនាគកាលិយ ដូចជា គម្ពីរមហាភារត (Mahābhārata) គម្ពីរហរិវំស (Harivamsa) គម្ពីរភគវតបុរាណ (Bhagavata Purana) និងគម្ពីរវិស្ណុបុរាណ (Vishnu Purana)។ ទេវកថារឿងព្រះក្រឹស្នៈហែកនាគកាលិយនិទានថា នាសម័យកាលមួយព្រះក្រឹស្ន និងមិត្តភក្តិបាននាំគ្នាទៅលេងនៅទន្លេកាលិន្ទីក្នុងតំបន់វ្រិន្ទាវន[១] ដោយមិនមានពលរាមទៅជាមួយ។ ដោយសារតែកម្តៅរបស់ព្រះអាទិត្យ អ្នកគង្វាលគោ និងក្មេងៗដែលទៅជាមួយក្រឹស្នបាននាំគ្នាផឹកទឹកនៅទន្លេនោះបណ្តាលឱ្យពុលស្លាប់។ បន្ទាប់ពីឃើញហេតុការណ៍នេះហើយ ក្រឹស្នមានកំហឹងយ៉ាងខ្លាំង ហើយទ្រង់បង្កើតនូវទឹកភ្លៀងពិសិដ្ឋមួយដើម្បីប្រោសជីវិតពួកគេឱ្យរស់ឡើងវិញ និងបានហៅនាគកាលិយចេញមកដើម្បីប្រយុទ្ធគ្នា[២] ឈុតឆាកប្រយុទ្ធគ្នាបានចាប់ផ្តើមឡើង ក្មេងៗទាំងនោះនាំគ្នាភ័យស្លន់ស្លោខ្លាចក្រឹស្នស្លាប់ ដោយសារតែនាគកាលិយចាប់ក្រវ៉ាត់កាយរបស់ទ្រង់យ៉ាងខ្លាំង។ ផ្ទុយទៅវិញ ក្រឹស្នបានចាប់ផ្តើមវាយហែកក្បាលនាគដោយព្រះហស្តទាំងពីររបស់ទ្រង់ រួចឡើងរាំសង្កត់លើក្បាលនាគកាលិយឱ្យចេញក្អួតស្ទើរនឹងស្លាប់[៣] ពេលនោះប្រពន្ធនាគកាលិយបានឃើញប្តី របស់ខ្លួនទ្រុឌទ្រោមរៀបនឹងស្លាប់ នាងក៏បានសុំអង្វរក្រឹស្នឱ្យដោះលែងប្តីរបស់ខ្លួន ហើយព្រះក្រឹស្នក៏យល់ព្រម ប៉ុន្តែពួកគេត្រូវនាំកូនចៅចុះទៅនៅសមុទ្រ[៤]

[១] O’Flaherty, Wendy Doniger 1975: p,221-224.

[២] ទេស សុធីរ, ម៉ក់ សោភា, ទិត្យ ច័ន្ទស្រីម៉ាច់, ប៊ូ ម៉ូលីនី, ង៉ែត ដារុធ ១៩៩៦: ទំ,១០។

[៣] Roveda 2005: p.79.

[៤] O’Flaherty, Wendy Doniger 1975: p,221-224.

អត្ថបទដោយ៖ ផួន ចាន់ដារីយ៉ា

ការបង្ហាញចម្លាក់ឈុតព្រះក្រឹស្ណហែកនាគកាលិយនៅតាមប្រាសាទខ្មែរ មានបង្ហាញនៅលើផ្តែរទ្វារ ជើងសសរផ្អោប នៅលើហោជាង និងជញ្ជាំងប្រាសាទ ក្នុងកាយវិការប្រយុទ្ធជាមួយនាគកាលិយ និងកាយវិការទ្រង់រាំនៅលើក្បាលនាគ និងហែកនាគជាពីរចំណែក ហើយក្នុងការឆ្លាក់ក្បាលនាគនោះទៀតសោត សិល្បករឆ្លាក់ជាពីរយ៉ាងគឺ ចំនួនសេស និងចំនួនគូ។ នៅសម័យអង្គរចម្លាក់ព្រះក្រឹស្ណហែកនាគ មានបង្ហាញឡើងដំបូងនៅលើផ្តែរទ្វារប្រាសាទក្រហម (រូបលេខ១) ដោយព្រះក្រឹស្ណឈររាំនៅលើក្បាលនាគ និងហែកនាគជាពីរចំណែក។ ចំណែកនៅលើផ្តែរប្រាសាទភ្នំជីសូរវិញ ក៏បានបង្ហាញអំពីចម្លាក់ព្រះក្រឹស្ណឈរក្រៀកហែកនាគជាពីរ (រូបលេខ២)។ នៅលើផ្តែរប្រាសាទវត្តភូ សិល្បករក៏បានឆ្លាក់រូបព្រះក្រឹស្ណឈររាំ និងហែកនាគជាពីរ (រូបលេខ៣)។ ចំណែកនៅលើហោជាងប្រាសាទព្រះវិហារវិញ ក៏មានបង្ហាញចម្លាក់ព្រះក្រឹស្ណឈររាំលើក្បាលនាគដែលបានហែកជាពីរ (រូបលេខ៤)។ រីឯចម្លាក់ក្រឡោតទាបនៅប្រាសាទបាភួនវិញ បានបង្ហាញឈុតក្រឹស្ណកំពុងប្រយុទ្ធជាមួយនាគកាលិយ ដោយព្រះបាទទាំងពីររបស់ទ្រង់កៀបនឹងខ្លួននាគ ហើយមិនតែប៉ុណ្ណោះក៏មានឆ្លាក់ជាមនុស្ស និងសត្វកំពុងតែមើលឆាកប្រយុទ្ធនោះផងដែរ (រូបលេខ៥)។ ជើងសសរផ្អោបនៅតួប៉មអាគ្នេយ៍របស់កំពែងប្រាសាទអង្គរវត្ត (រូបលេខ៦) និងសសរផ្អោបនៅភាគខាងជើងរបស់តួប៉មប្រាសាទបន្ទាយសំរែ (រូបលេខ៧) មានឆ្លាក់រូបព្រះក្រឹស្ណហែកនាគជាពីរចំណែកដែលមានលក្ខណៈស្រដៀងគ្នា ហើយនៅលើផ្តែរនៅច្រកទ្វារខាងកើតប្រាសាទបន្ទាយសំរែវិញ ក៏មានឆ្លាក់ឈុតរឿងនេះដូចគ្នាដែរ (រូបលេខ៨)។ នៅប្រាសាទព្រះខ័ន មានបំណែកផ្តែរមួយមានឆ្លាក់រូបព្រះក្រឹស្ណហែកនាគជាពីរដូចប្រាសាទដែលបានរៀបរាប់ពីខាងលើដែរ (រូបលេខ៩)។

សរុបជារួមមក ព្រះក្រឹស្ណមានការពេញនិយមខ្លាំងនៅក្នុងចម្លាក់ខ្មែរនាសម័យបុរាណ ហើយចម្លាក់រឿងព្រះក្រឹស្ណហែកនាគកាលិយ ជាឈុតមួយដែលខ្មែរបុរាណនិយមចូលចិត្តឆ្លាក់។ ចម្លាក់នេះទំនងជាលេចឡើងនៅកំឡុងសតវត្សរ៍ទី១០ ហើយសិល្បករនិយមឆ្លាក់ក្បាលនាគជាពីរយ៉ាង គឺក្បាលនាគចំនួនសេស និងចំនួនគត់គូ (ចំនួនគត់គូ ជាចំនួនដែលស្ថិតនៅក្នុងគោលការណ៍សូន្យ មានន័យថា "ស្លាប់"[៥]) និងមានបង្ហាញឡើងទម្រង់ជាការប្រយុទ្ធគ្នារវាងព្រះក្រឹស្ណនិងនាគកាលិយ ឬដូនកាលគេឆ្លាក់ក្នុងកាយវិការទ្រង់ឈររាំនៅលើក្បាលនាគ៕

[៥] Brand & Chuch 1992: 80.

អត្ថបទដោយ៖ ង៉ួន ចាន់ដារីយ៉ា

# ឯកសារយោង

**ទេស សុធីរ, ម៉ក់ សោភា, ទិត្យ ច័ន្ទស្រីម៉ាច, ប៊ូ ម៉ូលីនី, ង៉ែត ដារុធ**

*១៩៩៦, "សិក្សាចម្លាក់ទេវកថានៅលើផ្តែរទ្វារ ហោជាង និងអង្គហោជាង" ,សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របុរាណវិទ្យា ជំនាន់ទី៣ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។*

**Brand, Michael & Chuch Phoeun**

1992, *The age of Angkor*, Canberra, Australia.

**O'FLAHERTY, Wendy Doniger**

1975, *Hindu Mythus*, London, England.

**Vittorio, Roveda**

2005, *Images of Gods*, River Book, Bangkok.



រូបលេខ១៖ ផ្ដែររូបព្រះក្រឹស្ណហែកនាគនៅប្រាសាទក្រហម



រូបលេខ២៖ ផ្ដែររូបព្រះក្រឹស្ណហែកនាគនៅប្រាសាទភ្នំជីសូរ



រូបលេខ៣៖ ផ្ដែររូបព្រះក្រឹស្ណហែកនាគនៅប្រាសាទវត្តភូ (ប្រភពរូប៖ ម៉េង វ៉ាលី)



រូបលេខ៤៖ ឈុតព្រះក្រឹស្ណហែកនាគនៅលើហោរជាង ប្រាសាទព្រះវិហារ (ប្រភពរូប៖ លាក់ ស៊ីផាន់ណា)



រូបលេខ៥៖ ឈុតព្រះក្រឹស្ណហែកនាគនៅប្រាសាទបាភួន



រូបលេខ៦៖ ឈុតព្រះក្រឹស្ណហែកនាគនៅលើសសរផ្ដោប នៅអង្គរវត្ត (ប្រភពរូប៖ លាក់ ស៊ីផាន់ណា)

អត្ថបទដោយ៖ ផ្លូន ចាន់ដារីយ៉ា



រូបលេខ២៧៖ ឈុតព្រះក្រឹស្នហែកនាគនៅលើសសរផ្តោប នៅប្រាសាទបន្ទាយសំរែ



រូបលេខ២៨៖ ផ្តែររូបព្រះក្រឹស្នហែកនាគនៅប្រាសាទ បន្ទាយសំរែ



រូបលេខ២៩៖ បំណែកផ្តែររូបព្រះក្រឹស្នហែកនាគនៅប្រាសាទព្រះខ័ន

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION